## ការអនុវត្តច្បាប់មិនប្រតិសកម្ម (Non-Retroactivity)

វិធាននេះ បានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ (customary international law)។ វាហាមឃាត់នូវការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ (criminal responsibility) លើអំពើមុនច្បាប់ណាមួយចូលជាធរមាន (entry into force) ដែលអំពើនោះ ពីមុនមិនមែនជាបទល្មើស។ វិធាននេះជួយរារាំង មិនឲ្យមានសកម្មភាពបំពារបំពាន (arbitrary action) ដោយអាជ្ញាធររដ្ឋ តាមរយៈការធ្វើច្បាប់ដាក់ទោសទណ្ឌ។

សម្រាប់ប្រទេសកំមុនឡ (common law) វាជាធាតុផ្សំចាំបាច់នៃនីតិវិធីត្រឹមត្រូវ (due process)។ វិធានហាមមិនអនុវត្តប្រតិសកម្ម ក៏ពាក់ព័ន្ធផងដែរ នឹងគោលការណ៍នីត្យានុកូល (principle of legality)។ ក្នុងន័យនេះ បើអំពើនោះ ជាបទល្មើសក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយទើបតែត្រូវបានចាត់ជាបទល្មើសក្រោមច្បាប់ជាធរមាន វាមិនពាក់ព័ន្ធនឹងគោលការណ៍មិនប្រតិសកម្មទេ ដោយសារ ការកាត់ទោសផ្អែកតាមវិធានទំនៀមទម្លាប់ (ច្បាប់មិនសរសេរ)។

អនុសញ្ញាសិទ្ធិមនុស្ស មានចែងអំពីគោលការណ៍នេះ (មាត្រា១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង មាត្រា៧នៃ European Convention on Human Rights) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp.437-438)។

**ខ្លឹមសារបន្ថែម៖** គោលការណ៍មិនប្រតិសកម្ម មិនហាមឃាត់ឃាត់ការអនុវត្តទោសស្រាល ក្នុងច្បាប់មុន មុននឹងច្បាប់ថ្មីចូលជាធរមាន ដែលមានចែងនូវទោសធ្ងន់ជាងទេ។ ពាក្យ «ច្បាប់»ក្នុងន័យនេះមានខ្លឹមសារទូលាយ រាប់ទាំងច្បាប់អន្តរជាតិ និងច្បាប់របស់ប្រទេសកំមុនឡ (judge-made law) ផងដែរ។